**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១៣៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់ការប្រែក្លាយពី វិទ្យាស្ថាន ប៊ែលធី អន្តរជាតិ ទៅជា សាកលវិទ្យាល័យ ប៊ែលធី អន្តរជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការអប់រំ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា

-បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ

-បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៥ ស្តីពីការប្តូរឈ្មោះ " វិទ្យាស្ថានអាស៊ីប៉ាស៊ីភិច ទៅជា វិទ្យាស្ថាន ប៊ែលធី អន្តរជាតិ "

-តាមសំណើរបស់ក្រសួងអប់រំ យុវជន និង កីឡា

# សម្រេច

**មាត្រា ១ ៖** ទទួលស្គាល់ការប្រែក្លាយពី វិទ្យាស្ថាន ប៊ែលធី អន្តរជាតិ ( BELTEI International Institute ) ទៅជា **សាកលវិទ្យាល័យ ប៊ែលធី អន្តរជាតិ** ( BELTEI International University ) សរសេរកាត់ជាភាសាខ្មែរ " **ស.ប.អ.** " និង សរសេរកាត់ជាភាសាអង់គ្លេស " BIU "។

**មាត្រា ២ ៖** សាកលវិទ្យាល័យ ប៊ែលធី អន្តរជាតិ មានទីតាំងឋិតនៅដីឡូត៍លេខ ២១ ផ្លូវលេខ៣៦០ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ និង ឋិតនៅក្រោមឱវាទក្រសួងអប់រំ យុវជន និង កីឡា។

**មាត្រា ៣ ៖** សាកលវិទ្យាល័យ ប៊ែលធី អន្តរជាតិ ធ្វើការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រ និង បរិញ្ញាបត្រជាន់ខ្ពស់ លើមហាវិទ្យាល័យប្រាំមួយ និង វិទ្យាស្ថានមួយ ៖

-មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម

-មហាវិទ្យាល័យអប់រំ សិល្បៈ និង មនុស្សសាស្ត្រ

-មហាវិទ្យាល័យនីតិសាស្ត្រ និង វិទ្យាសាស្ត្រសង្គម

-មហាវិទ្យាល័យទេសចរណ៍ និង បដិសណ្ឋារកិច្ច

-មហាវិទ្យាល័យវិស្វកម្ម និង ស្ថាបត្យកម្ម

-មហាវិទ្យាល័យព័ត៌មានវិទ្យា និង វិទ្យាសាស្ត្រ

-វិទ្យាស្ថាន ប៊ែលធី អន្តរជាតិ

ទៅអនាគត សាកលវិទ្យាល័យ ប៊ែលធី អន្តរជាតិ ត្រូវរៀបចំកម្មវិធីសិក្សាលម្អិត តាមកម្រិត និង មុខជំនាញ ដើម្បីសុំការឯកភាពពី ក្រសួងអប់រំ យុវជន និង កីឡា។ សាកលវិទ្យាល័យនេះ អាចបើកសាខា មហាវិទ្យាល័យថ្មី មុខជំនាញថ្មី កម្រិតថ្មី ឬ ថ្នាក់ថ្មី ប្រភេទបណ្តុះបណ្តាលថ្មី ប្តូរឈ្មោះថ្មី ឬ ទីតាំងថ្មី ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និង កីឡា។

**មាត្រា ៤ ៖** សាកលវិទ្យាល័យ ប៊ែលធី អន្តរជាតិ ត្រូវរៀបចំក្រុមប្រឹក្សាភិបាលមួយ ដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និង កីឡា ដើម្បីពិនិត្យ និង សម្រេចលើគោលនយោបាយ ផែនការអភិវឌ្ឍកម្មវិធីសិក្សា និង ការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត។

**មាត្រា ៥ ៖** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យ ប៊ែលធី អន្តរជាតិ មានភារកិច្ច ៖

-ទទួលខុសត្រូវចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងសាកលវិទ្យាល័យ ប៊ែលធី អន្តរជាតិ និង ធានាឲ្យមានសុវត្ថិភាព និង សណ្តាប់ធ្នាប់សង្គម

-ទទួលខុសត្រូវក្នុងការជ្រើសរើសនិស្សិតឲ្យចូលរៀន និង ទទួលនិស្សិតឲ្យសិក្សាបន្ត តាមកម្មវិធីសិក្សារបស់ សាកលវិទ្យាល័យ ប៊ែលធី អន្តរជាតិ

-អនុវត្តតាមបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និង កីឡា ដែលកំណត់លើសកម្មភាពនៃការធានាគុណភាពអប់រំ

-រៀបចំតួនាទី ភារកិច្ច និង រចនាសម្ព័ន្ធគ្រប់គ្រងសាកលវិទ្យាល័យ និង បទប្បញ្ញត្តិសម្រាប់ការគ្រប់គ្រងការសិក្សា ឱ្យបានច្បាស់លាស់

-ធ្វើរបាយការណ៍ជូនក្រសួងអប់រំ យុវជន និង កីឡា តាមការកំណត់។

**មាត្រា ៦ ៖** និស្សិតសាកលវិទ្យាល័យ ប៊ែលធី អន្តរជាតិ ដែលបានរៀនចប់កម្មវិធីសិក្សា និង ទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រតាមកម្រិត និង មុខជំនាញ ដែលបានសិក្សា។ សញ្ញាបត្រនេះ ផ្តល់ឱ្យដោយសាកលវិទ្យាល័យ ប៊ែលធី អន្តរជាតិ ហើយត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និង កីឡា ក្នុងករណីសាកលវិទ្យាល័យ ប៊ែលធី អន្តរជាតិ បំពេញ និង អនុវត្តបាន តាមគោលការណ៍ និង បទដ្ឋានរបស់ក្រសួងអប់រំ យុវជន និង កីឡា។

**មាត្រា ៧ ៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា ប្រធានស្ថាប័នពាក់ព័ន្ធ និង ក្រុមប្រឹក្សាភិបាល រួមជាមួយ សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យ ប៊ែលធី អន្តរជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃ [illegible] ខែ កញ្ញា ឆ្នាំ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល ៖

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-សាលារាជធានីភ្នំពេញ
-រាជកិច្ច
-ដូចមាត្រា ៧ " ដើម្បីអនុវត្ត "
-ឯកសារ-កាលប្បវត្តិ